# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្តាល**

**សំណុំរឿងព្រហ្មទណ្ឌ**
លេខ ១៣៩៥ អក
ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០

**សាលក្រម**
លេខ ៨៦ "ផ.ក្រ"
ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្តាល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង ៩៖០០ នាទីព្រឹក ដោយមានសមាសភាព ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល ជាប្រធានក្រុមប្រឹក្សា
លោក [redacted] អនុប្រធានសាលាដំបូងខេត្តកណ្តាល ជាចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមសាលាដំបូងខត្តកណ្តាល ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង នៃសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១៣៩៥ អក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] ភ័ណ្ឌ ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ពុទ្ធី "រស់" ម្តាយឈ្មោះ [redacted] រ៉ា "រស់" នៅលើវ កម្រិតវប្បធម៌ថ្នាក់ទី៧ ជានីតិជន ទោសពីមុនគ្មាន (គេចខ្លួន) ។

២-ឈ្មោះ [redacted] **ឆៃលី ហៅ ខ្លី** ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] **ឆន** "រស់" ម្តាយឈ្មោះ [redacted] ហៀក "រស់" នៅលើវ ជានីតិជន ទោសពីមុនគ្មាន (គេចខ្លួន)។

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិ ។

ជាប់ចោទពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិព្រែកស៊ីង ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៥ ចំណុច៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ២២ និង ១០នាទី យប់បន្ទាប់ពីទទួលបានពត៌មានសមត្ថកិច្ចបានចុះបង្រ្កាបករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុចភូមិព្រែកស៊ីង ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល ហើយបានឆែកឆេររកឃើញថ្នាំញៀនចំនួន ១កញ្ចប់ទម្ងន់ ៥៨ ក្រាម ចំណែកឯជនត្រូវចោទបានរត់គេចខ្លួនបាត់ ។

**-បានឃើញ** របាយការណ៍លេខ **២១ រ.ប.ក** ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០ របស់អធិការដ្ឋាននគរបាលស្រុកកោះធំ ។

**-បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ **១០៨២ ដកសស** ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល ។

**-បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ **៧៤៨ ដកពស** ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល ។

**-បានឃើញ** ដីកាដំណោះស្រាយលេខ **៨៣៨ ដកដស** ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តកណ្តាល ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] **ភ័ណ្ឌ** អវត្តមាន ។

-ជនជាប់ចោទឈ្មោះ [redacted] **ឆែលី** អវត្តមាន ។

-អំណានកំណត់ហេតុចាប់យកវត្ថុតាង និងកំណត់ហេតុធ្វើតេស្តិ៍បឋមនិងវេចខ្ចប់វត្ថុតាង

**-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖** ស្នើសុំតម្កល់ការចោទប្រកាន់ដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរលេខ **៧៤៨ ដកពស** ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ ទុកជាបានការដដែល ។

-លោក [redacted] មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ បានសន្និដ្ឋានថា៖ ក្រោយពីប្រព្រឹត្តបទល្មើសរួច កូនក្តីខ្លួនបាននឹងកំពុងរស់នៅលាក់ខ្លួន ដែលនេះបង្ហាញពីការទទួលនូវទណ្ឌកម្មសង្គមរបស់កូនក្តីខ្លួន ម្យ៉ាងវិញទៀត កូនក្តីខ្លួនទើបតែប្រព្រឹត្តបទល្មើសជាលើកដំបូង ហើយវត្ថុតាងក៏មិនទាន់ត្រូវបានចែកចាយទៅដល់អ្នកប្រើប្រាស់ដែរ ហេតុនេះស្នើសុំឲ្យតុលាការពិចារណាផ្តល់ស្ថានសម្រាលទោសដល់កូនក្តីខ្លួនតាមមាត្រា ៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់ការសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ



Scanned with CamScanner

# សំអាងហេតុ

១-កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ២២ និង ១០នាទី យប់បន្ទាប់ពីទទួលបានពត៌មានសមត្ថកិច្ចបានចុះបង្ក្រាបករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុចភូមិព្រែកស៊ីង ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្ដាល ហើយបានឆែកឆេររកឃើញថ្នាំញៀនចំនួន ១កញ្ចប់ទម្ងន់ ៥៨ក្រាម ចំណែកឯជនត្រូវចោទបានរត់គេចខ្លួនបាត់ ។

២-តាមរបាយការណ៍លេខ ១៣៦/២១ របក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ របស់ប៉ុស្តិ៍នគរបាលរដ្ឋបាលសំពៅពូន បានបញ្ជាក់ថា ក្រោយពីទទួលបានពត៌មានពីប្រជាពលរដ្ឋថា មានការចែកចាយថ្នាំញៀន នៅចំណុចរោងចាំស្រូវស្រែប្រាំង ខាងក្រោយភូមិព្រែកស៊ីង ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្ដាល កម្លាំងប៉ុស្តិ៍បានចុះទៅដល់ទីតាំង ក៏ប្រទះឃើញឈ្មោះ [redacted] ភ័ណ្ឌ ឈ្មោះ [redacted] ឆៃលី ហៅ ខ្ចី និងម្នាក់ទៀតមិនស្គាល់ឈ្មោះ បានជិះម៉ូតូចំនួន ០២គ្រឿងម៉ាក Yamaha exciter ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1HI-9949 និងម៉ាកSuzuki Nex ពណ៌ស ពាក់ស្លាកលេខ ភ្នំពេញ 1HK-3094 ក្នុងបំណងគេចពីសមត្ថកិច្ច តែពេលជួបនឹងសមត្ថកិច្ច ឈ្មោះ [redacted] ភ័ណ្ឌ ឈ្មោះ [redacted] ឆៃលី ហៅ ខ្ចី និងម្នាក់ទៀតមិនស្គាល់ឈ្មោះ ក៏បានផ្ដួលម៉ូតូចោល រួចរត់ចូលដីស្រូវស្រែប្រាំងបាត់ទៅ ។ កម្លាំងប៉ុស្តិ៍ក៏បានធ្វើការឆែកឆេរ រកឃើញម្សៅក្រាមពណ៌សថ្លាចំនួន ០១កញ្ចប់ធំ នៅក្នុងកែបម៉ូតូម៉ាក Yamaha exciter រួមជាមួយនឹងប្រដាប់វេចខ្ចប់ថ្នាំញៀនមួយចំនួន គប្បីតុលាការពិចារណា ។

៣-តាមកំណត់ហេតុធ្វើតេស្ត និងវេចខ្ចប់វត្ថុតាង ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ របស់អធិការដ្ឋាននគរបាលស្រុកកោះធំ បានបញ្ជាក់ថា ម្សៅក្រាមពណ៌សថ្លា ចំនួន ០១កញ្ចប់ធំ ដែលសមត្ថកិច្ចរកឃើញនៅក្នុងកែបម៉ូតូរបស់ជនជាប់ចោទ គឺជាថ្នាំញៀនប្រភេទមេតំហ្វេតាមីន មានទម្ងន់សរុប ៥៨,៦៤ក្រាម ។

៤-តាមលិខិតលេខ ១២១៤/២១ អ.ត.អ.ជ.ប.គ.ញ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២១ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានសន្និដ្ឋានថា សំណាកជាគ្រឿងញៀនប្រភេទក្រាមថ្លា ឈ្មោះ មេតំហ្វេតាមីន ដែលមានកម្រិតភាពសុទ្ធ ៧៥,៤៦% ។ ដូច្នេះតាមការគណនាភាពសុទ្ធរបស់មេតំហ្វេតាមីនដែលចាប់ដកហូតបានគឺ៖ ៥៨,៦៤ក្រាមx៧៥,៤៦%=៤៤,២៤ក្រាម គប្បីតុលាការពិចារណា និងសម្រេចតាមច្បាប់ ។

៥-តាមរបាយការណ៍លេខ ២១ រ.ប.ក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០ របស់អធិការដ្ឋាននគរបាលស្រុកកោះធំ បានសន្និដ្ឋានថា ឈ្មោះ [redacted] ភ័ណ្ឌ និងឈ្មោះ [redacted] ឆៃលី ហៅ ខ្ចី ភេទប្រុស ពិតជាបានប្រព្រឹត្តករណី ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន។

៦-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំថា ស្នើសុំឲ្យរក្សាបទចោទប្រកាន់ទុកជាបានការដដែល គប្បីតុលាការពិចារណា ។



Scanned with CamScanner

៧-របាយការណ៍របស់សមត្ថកិច្ច និងភស្តុតាងក្នុងសំណុំរឿង ឃើញថា មានលក្ខណៈស៊ីសង្វាក់គ្នាយ៉ាងខ្លាំងទៅនឹងអង្គហេតុ ដែលអាចបញ្ជាក់បានថា នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០ នៅចំណុចភូមិព្រែកស៊ីង ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល ជនជាប់ចោទឈ្មោះ [redacted] ភ័ណ្ឌ និងឈ្មោះ [redacted] ឆែលី ហៅ ខ្លី ពិតជាបាននាំគ្នាធ្វើសកម្មភាពចែកចាយថ្នាំញៀនប្រភេទម៉ាទឹកកក ប្រាកដមែន ប៉ុន្តែក្រោយពេលជួបនឹងសមត្ថកិច្ច ជនជាប់ចោទក៏បានផ្តួលម៉ូតូ រួចរត់គេចខ្លួនបាត់តែម្តង ។

៨-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ភ័ណ្ឌ និងឈ្មោះ [redacted] ឆែលី ហៅ ខ្លី ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិព្រែកស៊ីង ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៥ ចំណុច៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៩-លោក [redacted] មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ បានសន្និដ្ឋានថា ក្រោយពីប្រព្រឹត្តបទល្មើសរួច កូនក្តីខ្លួនបាននឹងកំពុងរស់នៅលាក់ខ្លួន ដែលនេះបង្ហាញពីការទទួលនូវទណ្ឌកម្មសង្គមរបស់កូនក្តីខ្លួន ម្យ៉ាងវិញទៀត កូនក្តីខ្លួនទើបតែប្រព្រឹត្តបទល្មើសជាលើកដំបូង ហើយវត្ថុតាងក៏មិនទាន់ត្រូវបានចែកចាយទៅដល់អ្នកប្រើប្រាស់ដែរ ហេតុនេះស្នើសុំឲ្យតុលាការពិចារណាផ្តល់ស្ថានសម្រាលទោសដល់កូនក្តីខ្លួនតាមមាត្រា ៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ តុលាការយល់ឃើញថា បទល្មើសនេះកំពុងតែកើនឡើងខ្លាំងនាពេលបច្ចុប្បនេះ ហើយបានបង្កភាពចលាចលក្នុងសង្គមយ៉ាងធ្ងន់ធ្ងរ គប្បីត្រូវអនុវត្តច្បាប់ឲ្យបានតឹងរ៉ឹង និងមិនគួរមានការបន្ធូរបន្ថយទោសឡើយ ហេតុនេះគប្បីតុលាការមិនលើកយកការសន្និដ្ឋាននេះមកធ្វើការពិចារណាឡើយ ។

១០-តុលាការយល់ឃើញថា ក្រោយពីប្រព្រឹត្តបទល្មើសរួច ជនជាប់ចោទឈ្មោះ [redacted] ភ័ណ្ឌ និងឈ្មោះ [redacted] **ឆែលី ហៅ ខ្លី** បានរត់គេចខ្លួន និងមិនបានចូលខ្លួនតាមការកោះហៅរបស់តុលាការ ដែលនេះជាការបង្ហាញឲ្យឃើញពីចេតនាទុច្ចរិត ក្នុងការគេចវេសពីការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ហេតុនេះគប្បីតុលាការសម្រេចចេញដីកាបង្គាប់ឲ្យចាប់ខ្លួន-ឃុំខ្លួនជនជាប់ចោទទាំងពីរនាក់ តាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

១១-វត្ថុចាប់យករួមមាន ៖

-ថ្នាំញៀនប្រភេទម៉ាទឹកកកចំនួន ០១ កញ្ចប់ ទម្ងន់ ៥៨ ក្រាម ។

-ម៉ូតូចំនួន ០២គ្រឿង ម៉ាក Yamaha exciter ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1HI-9949 និងម៉ាកSuzuki Nex ពណ៌ស ពាក់ស្លាកលេខ ភ្នំពេញ 1HK-3094 ។

គប្បីតុលាការពិចារណា និងសម្រេចរឹបអូសតាមច្បាប់ ។



Scanned with CamScanner

# ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោស៖

ក-ឈ្មោះ [redacted] ភ័ណ្ឌ ភេទប្រុស អាយុ ២៦ឆ្នាំ ជាតិខ្មែរ (គេចខ្លួន)

ខ-ឈ្មោះ [redacted] ផែលី ហៅ ខ្ចី ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ (គេចខ្លួន)

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ ០៥ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០,០០០,០០០(ដប់លាន)រៀល ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិព្រែកស៊ីង ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៥ ចំណុច៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-បង្គាប់ឲ្យចាប់ខ្លួន-ឃុំខ្លួនឈ្មោះ [redacted] ភ័ណ្ឌ និងឈ្មោះ [redacted] ផែលី ហៅ ខ្ចី តាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣-វត្ថុចាប់យករួមមាន៖

-ថ្នាំញៀនប្រភេទម៉ាទឹកកកចំនួន ០១ កញ្ចប់ ទម្ងន់ ៥៨ ក្រាម **ត្រូវរឹបអូស** ។

-ម៉ូតូចំនួន ០២គ្រឿង ម៉ាក Yamaha exciter ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1HI-9949 និងម៉ាកSuzuki Nex ពណ៌ស ពាក់ស្លាកលេខ ភ្នំពេញ 1HK-3094 **ត្រូវរឹបអូស** ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ភ័ណ្ឌ ឈ្មោះ [redacted] ផែលី ហៅ ខ្ចី និងប្រកាសជាសាធារណៈ ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១ ។

បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃអង្គារ ៦កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

កណ្តាល,ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

កណ្តាល ថ្ងៃទី 28 ខែ 12 ឆ្នាំ២០២1

ក្រឡាបញ្ជី

[redacted]

Scanned with CamScanner